

ត្រូវបានបង្កើតជាថ្មី



Part 6/10

Resurrection

ដោយ ដេរេក ព្រីនស៍

សូមថ្វាយព្រះពរដល់ព្រះ ដែលបានជួបជាមួយលោកអ្នកម្តងទៀតនៅក្នុងសប្តាហ៍ថ្មីនេះ ដើម្បីចែកចាយ ជូនលោកអ្នក អំពីកូនសោសំខាន់ដែលនាំឲ្យជីវិតមានជោគជ័យ ដែលព្រះបានដាក់ក្នុងដៃរបស់ខ្ញុំ តាមរយៈ បទពិសោធន៍ផ្ទាល់ខ្លួន និងការបម្រើព្រះអង្គ អស់រយៈពេលជាច្រើនឆ្នាំ។

សប្តាហ៍នេះ ខ្ញុំនឹងបន្តជាមួយនឹងគោលសំខាន់ ដែលខ្ញុំបានចាប់ផ្តើមពីសប្តាហ៍មុន គឺ:«ការរស់ឡើងវិញ»។

ប៉ុន្តែ ជាដំបូង ខ្ញុំសូមអរគុណលោកអ្នកដែលបានចំណាយពេលសរសេរមកខ្ញុំ។ នៅចុងបញ្ចប់ការចែក ចាយរបស់ខ្ញុំនៅថ្ងៃនេះ យើងនឹងជម្រាបជូនលោកអ្នកអំពីអាស័យដ្ឋានសំបុត្រ ដើម្បីឲ្យលោកអ្នកអាចសរសេរ ផ្ញើមកយើងខ្ញុំ។ ការដែលឮពីលោកអ្នកថា ព័ន្ធកិច្ចរបស់យើងនេះបានជួយដល់លោកអ្នក ហើយជាព្រះពរដល់លោកអ្នក នោះមានន័យវិសេសវិសាលណាស់សម្រាប់យើងខ្ញុំ។ ដូច្នេះ សូមចំណាយពេលសរសេរមកយើងខ្ញុំកុំបី ខាន ទោះជាសំណេររបស់លោកអ្នក ជាសេចក្តីសង្ខេប ហើយមានលក្ខណៈផ្ទាល់ខ្លួនក៏ដោយ។

ឥឡូវនេះ សូមចូលមកកាន់គោលសំខាន់របស់យើង គឺ: «ការរស់ឡើងវិញ»។

សប្តាហ៍មុន ខ្ញុំបានពន្យល់ថា ដំណឹងល្អមានហេតុការណ៍ប្រវត្តិសាស្ត្រដ៏សំខាន់បីអំពីព្រះយេស៊ូវគ្រីស្ទ។ ហេតុការណ៍ទាំងបី គឺ ការសុគតរបស់ព្រះអង្គ ការបញ្ចុះព្រះអង្គទៅក្នុងផ្នូរ និងការដែលព្រះអង្គមានព្រះជន្មរស់ ពីសុគតឡើងវិញ។ ហេតុការណ៍ទាំងបីនេះ គឺជាស្នូល ជាគ្រឹះដ៏សំខាន់ ជាចំណុចកណ្តាល នៃរាជសាររបស់ដំណឹងល្អទាំងមូល។ ចំណុចកណ្តាលគឺ ព្រះយេស៊ូវ ហើយហេតុការណ៍ទាំងនោះមានចំណុចកណ្តាលនៅក្នុងការ សុគត ការបញ្ចុះទៅក្នុងផ្នូរ និងការមានព្រះជន្មរស់ពីសុគតឡើងវិញរបស់ព្រះអង្គ។

ការបញ្ជាក់លើកទីមួយនៃការរស់ឡើងវិញរបស់ព្រះគ្រីស្ទ គឺនៅក្នុងបទគម្ពីរទំនាយសញ្ញាចាស់។ យើងបាន មើលកាលពីសប្តាហ៍មុន ទៅឯគំរូដ៏ជាក់លាក់អំពីការនេះ ចេញពីទំនុកតម្កើងរបស់ព្រះបាទដាវីឌ និងចេញពី គម្ពីរហោរាហូសេ ដែលទាំងពីរសុទ្ធតែបានថ្លែងយ៉ាងច្បាស់ យ៉ាងសុក្រិត្យ និងយ៉ាងលម្អិត អំពីចំណុចនីមួយៗ អំពីការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។

ការបញ្ជាក់លើកទីពីរអំពីការរស់ឡើងវិញរបស់ព្រះគ្រីស្ទ ត្រូវបានប្រាប់ឲ្យដឹងដោយទីបន្ទាល់តាមរយៈ សាក្សីដែលគួរឲ្យទុកចិត្តបានជាច្រើននាក់ ជាអ្នកដែលបានឃើញព្រះអង្គនៅរស់ ក្រោយពីព្រះអង្គរស់ពីសុគត ឡើងវិញ។ នៅក្នុង ១កូរិនថូស ១៥:៥-៨ លោកប៉ូលបានរៀបរាប់ពីសាក្សីជាច្រើនដូចជា:

១. លោកកេផាស នេះគឺលោកពេត្រុស

២. សាវកទាំងដប់ពីរ

៣. ពួកអ្នកជឿជាង៥០០នាក់ ដែលឃើញព្រះអង្គក្នុងពេលតែមួយ

៤. លោកយ៉ាកុប ជាប្អូនប្រុសរបស់ព្រះយេស៊ូវ

៥. បន្ទាប់មក ពួកសាវកទាំងអស់ ហើយយើងមិនដឹងប្រាកដថាមានប៉ុន្មាននាក់ទេនៅចំណុចនេះ

៦. ហើយចុងក្រោយ គឺលោកប៉ូលខ្លួនឯងផ្ទាល់

ដូច្នេះ មានសាក្សីដែលអាចជឿទុកចិត្តបានជាង៥០០នាក់ ដែលបញ្ជាក់ប្រាប់ថា ព្រះយេស៊ូវបានរស់ពីសុគត ឡើងវិញ។

ការចែកចាយរបស់ខ្ញុំថ្ងៃនេះ និងពេញក្នុងសប្តាហ៍នេះ ខ្ញុំនឹងចែកចាយអំពីព្រះពរដែលមិនអាចវាស់ស្ទង់ បាន ដែលព្រះបានរៀបចំសម្រាប់យើង តាមរយៈការរស់ឡើងវិញរបស់ព្រះគ្រីស្ទ។ សម្រាប់ខ្ញុំ សេចក្តីនោះមាន លក្ខណៈលំដាប់លំដោយ ប្រកបដោយហេតុផល។ ទីមួយ បង្កើតបានជាហេតុការណ៍ប្រវត្តិសាស្ត្រ ហើយស្រប តាមបទគម្ពីរ អំពីការរស់ឡើងវិញរបស់ព្រះគ្រីស្ទ ហើយបន្ទាប់មក យើងឃើញអ្វីដែលកើតមានដល់យើង នៅ ក្នុងសេចក្តីមេត្តាករុណា និងការផ្គត់ផ្គង់របស់ព្រះ តាមរយៈការរស់ឡើងវិញរបស់ព្រះអង្គ។

ព្រះពរទីមួយ ដែលខ្ញុំនឹងនិយាយនៅថ្ងៃនេះគឺថា យើងអាចទទួលបានការកើតជាថ្មី ឬលោកអ្នកអាច ប្រើពាក្យថា លោកអ្នកត្រូវបានបង្កើតជាថ្មី។ នៅក្នុងសេចក្តីផ្តើមអំពីរឿងនេះ ខ្ញុំចង់ត្រឡប់ទៅមើលសេចក្តី ទំនាយរបស់ហោរាហូសេបន្តិច ជាសេចក្តីដែលយើងបានពិនិត្យមើលជាមួយគ្នាកាលពីសប្តាហ៍មុន។ គឺយើងងាក ទៅមើលតែមួយខទេ គឺហូសេ ៦:២:

> «នៅតែពីរថ្ងៃទៀត (គឺក្រោយពីរថ្ងៃ) ព្រះអង្គ[គឺជាព្រះអម្ចាស់]នឹងប្រោសពួកយើងឲ្យបានសះស្បើយ [នឹងនាំយើងមានជីវិតឡើងវិញ] នៅថ្ងៃទីបី ព្រះអង្គនឹងលើកពួកយើងឡើង ដើម្បីឲ្យយើងបានរស់នៅចំពោះព្រះភក្ត្រព្រះអង្គ។ » (RKOV)

មានការព្យាករទុកមកយ៉ាងច្បាស់អំពីការរស់ឡើងវិញ ដែលនឹងកើតឡើងនៅថ្ងៃទីបី។ ប៉ុន្តែ ដូចដែលខ្ញុំ បានចង្អុលបង្ហាញប្រាប់ពីសប្តាហ៍មុនហើយ ហោរាហូសេមិនបាននិយាយជាឯកវចនៈទេ គឺជាពហុវចនៈ។ ពោល គឺ លោកមិនបាននិយាយសម្រាប់តែតួអង្គព្រះគ្រីស្ទ តាមរយៈព្រះវិញ្ញាណបរិសុទ្ធថា «ព្រះអង្គនឹងប្រោសខ្ញុំ ឬព្រះអង្គនឹងលើកខ្ញុំឡើង» នោះឡើយ។ ប៉ុន្តែ លោកនិយាយជាពហុវចនៈ គឺ«ព្រះអង្គនឹងប្រោសពួកយើង ព្រះអង្គនឹងលើកពួកយើងឡើងវិញ»។ ដូច្នេះ ខ្ញុំបានចង្អុលបង្ហាញប្រាប់តាមការបំភ្លឺរបស់ព្រះវិញ្ញាណបរិសុទ្ធ ជា ពាក្យទំនាយក្នុងបទគម្ពីរដែលបើកសម្តែងថា យើងត្រូវបានរាប់បញ្ចូលនៅក្នុងការរស់ឡើងវិញរបស់ព្រះយេស៊ូវ ផងដែរ។ ព្រះយេស៊ូវសុគតជំនួសសេចក្តីស្លាប់របស់យើង ដើម្បីឲ្យយើងបានរួមជាមួយព្រះអង្គ ដោយកាជ្រមុជ ចូលទៅក្នុងការបញ្ចុះក្នុងផ្នូររបស់ព្រះអង្គ។ ហើយថា ដោយរួមជាមួយព្រះអង្គនៅក្នុងការបញ្ចុះទៅក្នុងផ្នូរ នោះយើងក៏រួមជាមួយព្រះអង្គនៅក្នុងការរស់ឡើងវិញរបស់ព្រះអង្គដែរ។

នៅក្នុងអេភេសូរ ២:៤-៦ លោកប៉ូលបញ្ជាក់សេចក្តីនេះយ៉ាងច្បាស់ថា:

> «ប៉ុន្តែ ព្រះដែលមានសេចក្តីមេត្តករុណាដ៏លើសលប់ ដោយព្រោះសេចក្តីស្រឡាញ់ជាខ្លាំងដែលព្រះអង្គ បានស្រឡាញ់យើង ទោះជាពេលដែលយើងបានស្លាប់ដោយសារអំពើរំលងរបស់យើងហើយក៏ដោយ ក៏ ព្រះអង្គបានប្រោសឲ្យយើងបានរស់ រួមជាមួយព្រះគ្រីស្ទ (អ្នករាល់គ្នាបានសង្គ្រោះដោយសារព្រះគុណ) ហើយនៅក្នុងព្រះគ្រីស្ទយេស៊ូវ ព្រះបានប្រោសឲ្យយើងរស់ឡើងវិញរួមជាមួយព្រះអង្គ ហើយឲ្យយើងអង្គុយ រួមជាមួយព្រះអង្គនៅស្ថានសួគ៌ដែរ» (RKOV)

សូមកត់សម្គាល់ពាក្យ «រួមជាមួយ» គឺមានបីដង ដែលម្តងៗសុទ្ធតែបង្ហាញពីបទពិសោធន៍ ដែលយើង មានចំណែកជាមួយព្រះយេស៊ូវ តាមរយៈជំនឿរបស់យើងលើការសុគតរបស់ព្រះអង្គ។ ព្រះបានប្រោសឲ្យយើង រស់រួមជាមួយព្រះគ្រីស្ទ ព្រះបានលើកយើងឡើងរួមជាមួយគ្នា ហើយព្រះឲ្យយើងអង្គុយរួមជាមួយគ្នា ឬឲ្យយើងសោយរាជ្យរួមជាមួយព្រះគ្រីស្ទ។ គ្រប់សេចក្តីទាំងនោះ សុទ្ធតែត្រូវបានលោកប៉ូលលើកឡើងជាទម្រង់ អតីតកាល។ នេះមិនមែនជាអ្វីមួយដែលនឹងកើតឡើងនោះទេ តែជាអ្វីម្យ៉ាងដែលបានសម្រេចរួចហើយ ហើយ អ្វីៗដែលតម្រូវពីយើង គឺឲ្យយើងចូលទៅក្នុងសេចក្តីនោះ ដោយជំនឿ។

ហើយបន្ទាប់មក មានអត្ថបទគម្ពីរដ៏សំខាន់មួយ នៅក្នុងជំពូកអំពីការរស់ឡើងវិញដ៏អស្ចារ្យនេះ ដែល យើងបានមើលជាមួយគ្នាជាច្រើនដងរួចមកហើយ គឺនៅក្នុង ១កូរិនថូស ១៥:៤៥-៤៧។ លោកប៉ូលប្រៀប ធៀបគ្នារវាងមនុស្សចាស់ និងមនុស្សថ្មី ដែលបានកើតឡើងដោយសារការសុគត និងការរស់ឡើងវិញរបស់ព្រះ យេស៊ូវគ្រីស្ទ។ នៅខ ៤៥ លោកមានប្រសាសន៍ថា:

> «ហេតុនេះនហើយបានជាមានសេចក្តីចែងទុកមកថា លោកអ័ដាម ដែលជាមនុស្សមុនដាំបូង បានត្រឡប់ជា មានព្រលឹងរស់នឡើង តែនលាកអ័ដាមចុងនព្តាយបង្អស់ ត្រឡប់ជាវិញ្ញាណដែលផ្តល់ជីវិត។ [ដូច្នេះ នៅ ចំណុចនេះ លោកប៉ូលថ្វាយបរមងារព្រះយេស៊ូវថា «អ័ដាមចុងក្រោយ»។ ហើយបន្ទាប់មក ក្នុងខ ៤៧ លោក ថ្លែងថា:] មនុស្សទីមួយ កើតចេញពីដីមក គឺធ្វើពីធូលីដី រីឯមនុស្សទីពីរវិញ មកពីស្ថានសួគ៌។» (RKOV)

លោកប៉ូលបានឲ្យបរមនាមព្រះយេស៊ូវថា «មនុស្សទីពីរ»។ ឥឡូវនេះ យើងដាក់នាមទាំងពីរនេះ ដោយឡែកពីគ្នា ប៉ុន្តែដាក់តាមលំដាប់ដ៏ត្រឹមត្រូវ។ ទីមួយ ព្រះយេស៊ូវ ជាអ័ដាមចុងក្រោយ ហើយទីពីរ ព្រះអង្គជាមនុស្សទីពីរ។ ក្នុងនាមជាអ័ដាមចុងក្រោយ ព្រះអង្គបានទទួលរងសេចក្តីអាក្រក់ទាំងស្រុង ដែលត្រូវធ្លាក់មកលើពូជពង្សអ័ដាមទាំងអស់ តាមរយៈអំពើបាប និងការបះបោរ។ ការសុគតរបស់ព្រះយេស៊ូវ គឺជាការ ដែលព្រះអង្គទទួលរងផលនៃអំពើបាប និងការបះបោរ របស់ពូជពង្សអ័ដាម។

បន្ទាប់មក នៅពេលព្រះអង្គរស់ពីសុគតនៅថ្ងៃទីបី ក្នុងនាមជាមនុស្សទីពីរ ព្រះអង្គ គឺជាសិរិសានៃពូជពង្ស ថ្មី ដែលនោះហើយជាគោលបំណងរបស់ព្រះ ក្នុងការដែលព្រះយេស៊ូវបានសុគត ហើយមានព្រះជន្មរស់ឡើងវិញ ដើម្បីបញ្ចប់មរតករបស់អ័ដាម ដោយការសុគតរបស់ព្រះអង្គ ហើយបន្ទាប់មក បើកផ្លូវឲ្យអស់អ្នកដែលជឿចូល ទៅកាន់ពូជពង្សថ្មី ជាពូជពង្សដែលមានព្រះយេស៊ូវគ្រីស្ទជាសិរិសា។

របៀបដែលយើងអាចចូលទៅក្នុងមរតកថ្មីនេះ ហើយត្រឡប់ជាសមាជិកនៃពូជពង្សថ្មីនេះ នៅក្នុង ព្រះគ្រីស្ទ នោះគឺត្រូវបានបង្កើតជាថ្មី ឬដែលយើងអាចហៅថា កើតជាថ្មី។ ក្នុងន័យម្យ៉ាង ពាក្យ «បង្កើត» បញ្ជាក់អំពីចំណែករបស់ឪពុកក្នុងការផ្តល់កំណើត។ ហើយនេះ គឺជាព្រះវរបិតាហើយ ដែលតាមរយៈជំនឿរបស់ យើងក្នុងព្រះយេស៊ូវគ្រីស្ទ ទ្រង់បង្កើតយើងជាថ្មី។ ប៉ុន្តែ ប្រាកដហើយ អ្នកដែលត្រូវបានបង្កើត ក៏ត្រូវប្រសូត មកដែរ។ ដូច្នេះ ព្រះគម្ពីរប្រើឃ្លាទាំងពីរ។ សាវកពេត្រុសបានថ្លែងពីការនេះ នៅក្នុង ១ពេត្រុស ១:៣ ថា:

> «សូមសរសើរតម្កើងដល់ព្រះ ជាព្រះវរបិតារបស់ព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់របស់យើងរាល់គ្នា ដែលព្រះអង្គបានបង្កើតយើងឡើងជាថ្មី តាមព្រះហឫទ័យមេត្តាករុណាដ៏ធំរបស់ព្រះអង្គ ដើម្បីឲ្យយើងរាល់គ្នា មានសង្ឃឹមដ៏រស់ តាមរយៈការមានព្រះជន្មរស់ពីស្លាប់នឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ...» (RKOV)

ដូច្នេះ ដោយការទទួលយកដោយជំនឿ រួមជាមួយព្រះយេស៊ូក្នុងការសុគត ការបញ្ចុះទៅក្នុងផ្នូរ និង ការរស់ពីសុគតឡើងវិញ នោះយើងបានឆ្លងកាត់ជាមួយព្រះអង្គ ចេញពីប្រព័ន្ធចាស់ គឺពីមនុស្សចាស់ ចូលមក ក្នុងប្រព័ន្ធថ្មី ឬមកជាមនុស្សថ្មី។ យើងត្រូវបានបង្កើតជាថ្មី ដោយព្រះចេស្តារបស់ព្រះ មកជាពូជពង្សថ្មី ជាពូជពង្សដែលមានព្រះយេស៊ូគ្រិស្តជាព្រះសិរិសា។ ខ្ញុំហៅពូជពង្សនេះថា «ពូជពង្សអេម៉ាញូអែល» គឺជា ពូជពង្សដែល «ព្រះទ្រង់គង់ជាមួយយើង»។

នេះហើយជាគោលបំណងនៃការសុគត និងការរស់ពីសុគតឡើងវិញរបស់ព្រះយេស៊ូវ។ កាលបើយើង ត្រូវបានបង្កើតជាថ្មី ឬកើតជាថ្មីហើយ ចាប់ពីពេលនោះមក ព្រះគ្រីស្ទ ទ្រង់ជាប្រភពនៃជីវិតដ៏អស់កល្បជានិច្ច ទ្រង់គង់នៅជាធរមាននៅខាងក្នុងយើង។ យើងមានប្រភពជីវិតមួយថ្មីទាំងស្រុង ដែលនៅក្នុងព្រះគ្រីស្ទ និង នៅស្ថានសួគ៌។ សេចក្តីនេះត្រូវបានសាវកប៉ូលរៀបរាប់ប្រាប់នៅក្នុងកូឡុស ៣:១-៤ ដែលលោកបានថ្លែងថា:

> «ដូច្នេះ ប្រសិនបើអ្នករាល់គ្នាបានរស់នឡើងវិញជាមួយព្រះគ្រីស្ទមែន[គឺបានរួមជាមួយព្រះអង្គក្នុងការរស់ ពីសុគតឡើងវិញ] ចូរស្វែងរកអ្វីៗដែលនៅស្ថានលើ ជាស្ថានដែលព្រះគ្រីស្ទគង់ខាងស្តាំព្រះហស្តរបស់ព្រះ នេះវិញ។[នេះគឺជាកន្លែងមរតករបស់យើងនៅស្ថានសួគ៌ នៅលើបល្ល័ង្ករួមជាមួយព្រះយេស៊ូវ]ចូរគិតពី អ្វីៗដែលនៅខាងលើ កុំគិតពីអ្វីៗដែលនៅផែនដីឡើយ [នេះជាដំបូន្មានដ៏សំខាន់ ព្រោះគំនិតយើងគិតទៅ ទីណា នេះវានឹងកំណត់ទិសដៅក្នុងជីវិតរបស់យើងនៅទីនេះ។ បន្ទាប់មក លោកបន្តជាមួយនឹង គោលសំខាន់ក្នុងការរួមជាមួយនេះថា៖] ដ្បិតអ្នករាល់គ្នាបានស្លាប់ហើយ [គឺយើងបានស្លាប់នៅពេលព្រះ គ្រីស្ទបានសុគត ដ្បិតការសុគតរបស់ព្រះអង្គ គឺជាការស្លាប់របស់យើង] ឯជីវិតរបស់អ្នករាល់គ្នាក៏បាន លាក់ទុកជាមួយព្រះគ្រីស្ទក្នុងព្រះដែរ។ [នេះជាសុវត្ថិភាពដ៏អស្ចារ្យ ក្នុងការដែលជីវិតមួយ ដែលត្រូវបានលាក់ទុកជាមួយព្រះគ្រីស្ទ នៅក្នុងព្រះ។ ហើយបន្ទាប់មក លោកបន្ត ដោយសង្ខេបសេចក្តីនេះថា:] ពេល ព្រះគ្រីស្ទ ដែលជាជីវិតរបស់អ្នករាល់គ្នាលេចមក នេះអ្នករាល់គ្នាក៏នឹងលេចមក ជាមួយព្រះអង្គក្នុងសិរីល្អ ដែរ។» (RKOV)

សូមកត់សម្គាល់ នេះជាឃ្លាដ៏អស្ចារ្យដែលអត្ថន័យ មិនអាចវាស់ស្ទង់បាន គឺ «ព្រះគ្រីស្ទទ្រង់ជាជីវិតរបស់ យើង»។ តើអ្វីទៅដែលអស្ចារ្យជាងនេះ? គ្រប់ទាំងសេចក្តីត្រូវការ គឺត្រូវបានគ្របដណ្តប់ដោយ សេចក្តីពិតមួយ គឺដែលព្រះគ្រីស្ទរស់ពីសុគតឡើងវិញ ប្រកបដោយសិរីរុងរឿង និងមានជ័យជំនះ ទ្រង់ជាជីវិត របស់យើង។ គ្មានអ្វីដែលអាចយកជ័យជំនះ ឬអាចយកឈ្នះលើជីវិតនេះបានឡើយ គឺជាជីវិតដែលមិនអាច បរាជ័យ មិនអាចបំផ្លាញបាន ហើយនៅអស់កល្បជានិច្ច។

លោកប៉ូលអនុវត្តការនេះ សម្រាប់បទពិសោធន៍របស់លោក ហើយសេចក្តីនេះក៏អនុវត្តសម្រាប់បទ ពិសោធន៍របស់យើងដែរ។ នៅក្នុង ២កូរិនថូស ៤:១៦ លោកប៉ូលថ្លែងថា:

> «ហេតុនេះយើងមិនរសាយចិត្តនឡើយ ទោះបើមនុស្សខាងក្រៅរបស់យើងកំពុងតែពុករលួយទៅក៏ដោយ តែ មនុស្សខាងក្នុងកំពុងតែកើនឡើងជាថ្មី ពីមួយថ្ងៃទៅមួយថ្ងៃ។ » (RKOV)

នេះជារាជសារមួយដ៏ល្អដែលលើកទឹកចិត្តយើងជាខ្លាំង។ យើងមិនត្រូវរសាយចិត្តឡើយ។ អ្វីៗមើលទៅ ហាក់ដូចជាពិបាក ស្ថានភាពក្នុងជីវិតខាងក្រៅ មើលទៅហាក់ដូចជាចូលមកប្រឆាំងនឹងយើង ប៉ុន្តែ លោកប៉ូល បញ្ជាក់ថា យើងត្រូវបានតភ្ជាប់ជាមួយព្រះយេស៊ូវ។ ដោយជំនឿ តាមរយៈព្រះវិញ្ញាណបរិសុទ្ធ យើងមានប្រភព នៃជីវិតមួយនៅខាងក្នុង ហើយមនុស្សខាងក្នុងរបស់យើង ត្រូវបានកែឡើងជាថ្មីជាប់ជានិច្ច ដោយប្រភពនៃ ជីវិតនៅក្នុងយើង គឺព្រះគ្រីស្ទដែលបានរស់រស់ពីសុគតឡើងវិញ ប្រកបដោយសិរីរុងរឿង។ ខ្ញុំសូមបញ្ចប់ដោយ ពាក្យនេះជាមួយលោកអ្នក គឺ: «ព្រះគ្រីស្ទទ្រង់ជាជីវិតរបស់យើង»។

យើងអស់ពេលហើយសម្រាប់ថ្ងៃនេះ។ ខ្ញុំនឹងវិលត្រឡប់មកជួបជាមួយលោកអ្នកជាថ្មីម្តងទៀតនៅថ្ងៃ ស្អែក តាមពេលវេលា និងម៉ោងកំណត់។ ថ្ងៃស្អែក ខ្ញុំនឹងបន្តគោលសំខាន់អំពីការរស់ឡើងវិញបន្តទៀត ហើយ ខ្ញុំនឹងចែកចាយពីរបៀបដែលព្រះគ្រិស្តដែលបានរស់ឡើងវិញ ត្រឡប់ជាសេចក្តីសុចរិតរបស់យើង។ សូមបន្ត សិក្សាជាមួយខ្ញុំកុំបីខាន សូមព្រះអម្ចាស់យេស៊ូវទ្រង់ប្រទានពរ។

ផតខាស
ប្រតិចារិក: RP-R109-101-KHM
បច្ចុប្បន្នភាពចុងក្រោយ: 27 Nov 2026
គេហទំព័រ: Derekprince.com/km/resources

